មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

ភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១០

## ការជំនុំជំរះដោយអយុត្តិធម៌ចំពោះករណីអ្នកស្រី មូរ សុខហួរ ឆ្លុះបញ្ចាំងពីប្រព័ន្ធតុលាការបែកបាក់របស់កម្ពុជា

### មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចេញផ្សាយការវិភាគច្បាប់ ទាក់ទងនឹងភាពយុត្តិធម៌នៃនីតិវិធីតុលាការដែលនាំអោយមានកាផ្តន្ទាទោស អ្នកតំណាងរាស្ត្រ មូរ សុខហួរ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ថ្ងៃនេះចេញផ្សាយការវិភាគច្បាប់ទាក់ទងនឹងភាពយុត្តិធម៌ នៃនីតិវិធីតុលាការ ដែលនាំអោយមានកាផ្តន្ទាទោស នៅតុលាការកំពូល ដោយទាត់ចោលបណ្តឹងសាទុក្ខរបស់អ្នកស្រី មូរ សុខហួរ ដែលជាអ្នកតំណាងរាស្ត្រគណបក្សប្រឆាំង និងជាបេក្ខជនពានរង្វាន់សន្តិភាព ដែលប្តឹងពីបទបរិហាកេរ្តិ៍ដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។

ការវិភាគបានបង្ហាញថា នីតិវិធីតុលាការមានភាពអយុត្តិធម៌ដោយបានកត់សំគាល់អំពីវិសមភាពចំពោះមុខច្បាប់ ការបំភិតបំភ័យមេធាវីរបស់អ្នកស្រី មូរ សុខហួរ ដែលធ្វើអោយអ្នកស្រីគ្មានជំនួយមេធាវីស្របច្បាប់ និងមានការគ្រប់គ្រងតុលាការពីភាគីវិវាទ ដោយនាយករដ្ឋមន្ត្រី និងគណបក្សប្រជាជនរបស់លោកប្រកបដោយប្រសិទ្ធិភាព។ ការវិភាគបានដាក់សវនាការរបស់អ្នកស្រី មូរ សុខហួរ ក្នុងបរិបទទូលំទូលាយ ដោយតុលាការមិនឯករាជ្យដែលជាញឹកញយ ត្រូវបានប្រើប្រាស់ជាឧបករណ៍បំភិតបំភ័យសំលេងអ្នកប្រឆាំង គ្មានទំនុកចិត្តពីប្រជាពលរដ្ឋខ្មែរ ហើយជាធម្មតាឧកខានមិនបានបំពេញ ករណីកិច្ចធម្មនុញ្ញរបស់ខ្លួន ក្នុងការការពារសិទ្ធិមនុស្សជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

ប្រព័ន្ធតុលាការកម្ពុជាខូចខាតជាដំណំ។ បើគ្មានការអនុវត្តកែទម្រង់ពិតប្រាកដ ដើម្បីបង្ហាញបញ្ហាដ៍ជ្រៅនៃការជ្រៀតជ្រែកនយោបាយ ការរីករាលដាលនៃអំពើពុក

រល្អួយ និងសមត្ថភាពមានកម្រិតក្នុងការយល់ដឹង និងការអនុវត្តបទដ្ឋានសិទ្ធិមនុស្ស នោះទេ ឧបសគ្គជារចនាសម្ព័ន្ធមួយនេះ នៅតែមិនអាចការពារពលរដ្ឋខ្មែរដើម្បីអោយទទួលបាននូវសិទ្ធិមនុស្ស និងសិទ្ធិធម្មនុញ្ញរបស់ខ្លួនបានឡើយ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សូមអំពាវនាវធ្វើយុទ្ធនាការកំណែទម្រង់តុលាការ ដោយរួមបញ្ចូលទាំងការប្រើប្រាស់យន្តការក្នុងស្រុក ក្នុងតំបន់ និងអន្តរជាតិ ដើម្បីទាមទារអោយមានតុលាការយុត្តិធម៌និងមានដំណើរការល្អ ដើម្បីការពារសេរីភាពជាមូលដ្ឋាន សិទ្ធិដីធ្លី និងជីវភាពប្រចាំថ្ងៃនៃពលរដ្ឋកម្ពុជា។

ការវិភាគច្បាប់ នឹងដាក់ជូនជាភាសាខ្មែរ និងភាសាអង់គ្លេសនៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា www.sithi.org និង គេហទំព័រ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា www.cchrcambodia.org

ពត៌មានបន្ថែមសូមទាក់ទង៖

លោក អ៊ូ វីរៈ ប្រធាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
ទូរសព្ទ: +៨៥៥ -១២-៤០៤០៥១
អ៊ីម៉ែល: ouvirak@cchrcambodia.org